# ស្តង់ដារសហគមន៍លើបណ្តាញ BLACKBERRY

BlackBerry មានបំណងផ្តល់នូវសេវាកម្ម និងសហគមន៍លើបណ្តាញរបស់យើង ដូចជា BBM Channels ដើម្បី ជាកន្លែងកម្សាន្ត និងមានសុវត្ថិភាពសម្រាប់មនុស្សដើម្បីចែករំលែកគំនិត និងព័ត៌មានជាមួយមនុស្សផ្សេង ទៀតដែលមានចំណាប់អារម្មណ៍ស្រដៀងគ្នា។ ដើម្បីធានាថាយើងរក្សានូវបរិស្ថានស្វាគមន៍យ៉ាងរាក់ទាក់ ចំពោះអ្នកប្រើប្រាស់របស់យើង ជាការសំខាន់ដែលអន្តរសកម្មភាពអ្នកប្រើប្រាស់ត្រូវបានធ្វើដូច្នេះ នៅក្នុង របៀបមួយដែលបំពេញតាមស្តង់ដារខាងក្រោម៖

1. **ត្រូវចេះគោរព។** មិនត្រូវបង្ខូចកេរឈ្មោះ រំលោភបំពាន យាយី សម្លុតកំហែង ឈ្លបមើលដោយ ខុសច្បាប់ គំរាមកំហែង បង្កគ្រោះថ្នាក់ ឬក្រៅពីនេះរំលោភសិទ្ធិស្របច្បាប់ផ្សេងៗ (ដូចជា សិទ្ធិភាពជាឯកជនភាព និងសិទ្ធិសាធារណៈ និងសិទ្ធិកិច្ចសន្យា និងកម្មសិទ្ធិបញ្ញា) របស់ អ្នកដទៃ។

2. **ត្រូវចេះគួរសម។** មិនត្រូវចុះផ្សាយ ដាក់ ដាក់ទៅប្រព័ន្ធ ចែកចាយ ឬផ្សព្វផ្សាយប្រធានបទ ឈ្មោះ សម្ភារៈ ឬព័ត៌មានណាមួយដែលមិនសមរម្យ ដែលមិនគោរពចំពោះសាសនា ដែល រំលោភ ដែលអាសគ្រាម ដែលមិនទៀងត្រង់ ឬដែលមិនស្របច្បាប់។

3. **ត្រូវគោរពច្បាប់។** មិនត្រូវរំលោភច្បាប់ ឬបទបញ្ញាពាក់ព័ន្ធណាមួយ ឬដាក់ ឬបញ្ជូនកម្មវិធី ចារកម្ម កម្មវិធីព្យាបាទ មេរោគ ឬអ្វីមួយដែលអាចបង្អាក់សេវាកម្ម ឬបង្កគ្រោះថ្នាក់ដល់អ្នក ផ្សេងទៀត។

4. **ត្រូវនិយាយការពិត។** មិនត្រូវក្លែងបន្លំជាមនុស្ស ឬអង្គភាពណាមួយ ឬថ្លែងខុសពីការពិត ឬក្រៅ ពីនេះបង្ហាញខុសនូវការជាប់ទាក់ទងរបស់អ្នកជាមួយមនុស្ស ឬអង្គភាព ឬបង្កើតអត្តសញ្ញាណ ក្លែងក្លាយដើម្បីឱ្យអ្នកដទៃយល់ខុស ឬដែល បណ្តាលឱ្យអ្នកដទៃជួបនូវបទពិសោធន៍ដែល មិនបានរំពឹងទុក ដែលខកចិត្ត ឬដែលមិនយុត្តិធម៌ និង

5. **ត្រូវចូលរួម។** មិនត្រូវ "ផ្ញើសារឥតបានការ" ឬផ្សែអង្គាសប្រាក់អ្នកដទៃដោយគ្មានការយល់ព្រម ពីពួកគេ ដែលរួមមានការដាក់ការចម្លង ឬការដាក់ស្រដៀងគ្នាជាច្រើន ឬការដាក់មាតិកា ដែលមិនពាក់ព័ន្ធនឹងការពិភាក្សា។

ស្តង់ដាររបស់យើងត្រូវបានរចនាឡើង ដើម្បីជួយបន្ថែមទៀតដល់គោលបំណងរបស់យើងក្នុងការបង្កើត បទពិសោធន៍ដែលគួរឲ្យចាប់អារម្មណ៍ ដែលមានតម្លៃ ដែលច្នៃប្រឌិត និងសំខាន់បំផុតដែលគួរឲ្យ រីករាយសម្រាប់អ្នកប្រើប្រាស់របស់យើង ។